# ៤. ប្រព័ន្ធពិនិត្យតាមដាន វាយតម្លៃ និង របាយការណ៍

## សេចក្តីផ្តើម

ការពិនិត្យតាមដាន និង ដំណើរការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) និង កម្មវិធីគាំទ្រវិស័យអប់រំ (ESSP) ផ្តោតលើវិសាលភាពនៃការសម្រេចវត្ថុបំណងគោលនយោបាយ និង ចំណុចដៅនានាជាមូលដ្ឋានប្រចាំឆ្នាំ ។ ការពិនិត្យឡើងវិញនេះ បានបង្ហាញពីការផ្លាស់ប្តូរពីគោលវិធីដែលធ្លាប់អនុវត្តកន្លងមក ទៅជាការពិនិត្យតាមដានដែលផ្តោតទៅលើការពិនិត្យតាមដានការរីកចម្រើននៃសកម្មភាពនីមួយៗ និង កិច្ចបញ្ជិការគណនេយ្យរបស់គំរោង និង កម្មវិធីនានា ដែលជាធនធានបញ្ចូលសម្រាប់វិស័យអប់រំ ។ អាំងឌីកាទ័រ និងចំណុចដៅសម្រាប់ការបំពេញការងារវិស័យអប់រំឆ្នាំ ២០០៦-១០ មានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ "ក" ។ ការពិនិត្យតាមដានការរីកចម្រើនរបស់សកម្មភាពនានា ទាមទារសម្រេចឱ្យបាននូវវត្ថុបំណងទាំងឡាយ ដូចមានបញ្ជាក់នៅក្នុងតារាងម៉ាទ្រិកសកម្មភាពគោលនយោបាយរួម ក្នុងឧបសម្ព័ន្ធ "ខ" ។ តារាងម៉ាទ្រិកនេះ គឺជាប្រធានបទសម្រាប់ក្រសួងអប់រំ យុវជន និង កីឡា អ្នកផ្តល់ជំនួយ និង អង្គការក្រៅរដ្ឋាភិបាល ធ្វើការពិនិត្យឡើងវិញរួមគ្នានៅពេលក្រោយទៀត ហើយត្រូវធ្វើការកែលំអជាទៀងទាត់ ។

### ៤.១ រចនាសម្ព័ន្ធនៃការពិនិត្យតាមដាន និង ការវាយតម្លៃការបំពេញការងារវិស័យអប់រំ

រចនាសម្ព័ន្ធនៃប្រព័ន្ធពិនិត្យតាមដានកម្មវិធីគាំទ្រវិស័យអប់រំ គឺអាស្រ័យទៅលើកិរិតទទួលខុសត្រូវដូចខាងក្រោម ។ រចនាសម្ពន្ធ័នេះ រួមបញ្ចូលទាំងការពង្រីកប្រព័ន្ធពិនិត្យតាមដានស្តង់ដា និង គុណភាពរបស់កម្មវិធី និង របស់វិស័យទាំងមូល តាមរយៈអគ្គនាយកដ្ឋាន និង នាយកដ្ឋាននានា ។

- **ក-** *ការពិនិត្យតាមដានការអនុវត្ត* : សម្របសម្រួលដោយមន្ត្រីអប់រំ ថ្នាក់ស្រុក-ខ័ណ្ឌ គណៈកម្មការទ្រទ្រង់សាលារៀន និង គណៈកម្មការអប់រំសម្រាប់ទាំងអស់គ្នា ថ្នាក់ឃុំ-សង្កាត់ ។
- **ខ-** *ការពិនិត្យតាមដានការរីកចម្រើនរបស់កម្មវិធី* : សម្របសម្រួលដោយមន្ត្រីអប់រំ ខេត្ត-ក្រុង ជាពិសេស មន្ត្រីការិយាល័យផែនការ និង អធិការកិច្ច និង ការិយាល័យហិរញ្ញវត្ថុ ខេត្ត-ក្រុង និង នាយកដ្ឋានជំនាញ លើកម្មវិធីជាអាទិភាព និង កម្មវិធីផ្សេងទៀត ។
- **គ-** *ការពិនិត្យតាមដានការបំពេញការងារវិស័យអប់រំ* : សម្របសម្រួលដោយអធិការដ្ឋានអប់រំ នាយកដ្ឋានផែនការ គណៈកម្មការជាតិអប់រំសម្រាប់ទាំងអស់គ្នា និង នាយកដ្ឋានជំនាញ ។
- **ឃ-** *ការពិនិត្យតាមដានផលប៉ះពាល់របស់កម្មវិធី* : សម្របសម្រួលដោយនាយកដ្ឋានផែនការ ក្នុងកិច្ចសហការជាមួយនាយកដ្ឋានជំនាញ និង អង្គភាពពាក់ព័ន្ធ ។

ង- *ការធ្វើសវនកម្មលើការបំពេញការងាររបស់ប្រព័ន្ធ* ៖ សម្របសម្រួលដោយអធិការដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អធិការដ្ឋានអប់រំ នាយកដ្ឋានសវនកម្មផ្ទៃក្នុង សវនកម្មរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អាជ្ញាធរជាតិសវនកម្ម ។

គោលការណ៍ណែនាំប្រតិបត្តិសម្រាប់លំដាប់ថ្នាក់នីមួយៗ បានរៀបចំឡើង និង បានដាក់ឱ្យអនុវត្ត ព្រម ទាំងត្រូវបន្តពិនិត្យឡើងវិញ និង ធ្វើការអភិវឌ្ឍផងដែរ ។ ក្របខ័ណ្ឌការងារនេះបានបង្កើតជាមូលដ្ឋានគ្រឹះផងដែរ សម្រាប់ការកសាងសមត្ថភាព ដូចមានបញ្ជាក់នៅក្នុងផ្នែកទី ៣.២.១ ។

## ៤.២ ការគ្រប់គ្រងលើការងារពិនិត្យតាមដាន និង ការវាយតម្លៃការបំពេញការងារវិស័យអប់រំ

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និង កីឡា នឹងដឹកនាំការពិនិត្យឡើងវិញជាន់ខ្ពស់មួយ ដើម្បីរកឱ្យឃើញ នូវគោលនយោបាយ និង យុទ្ធសាស្ត្រជាក់ស្តែង ដែលអាចមានឥទ្ធិពលទៅលើការអនុវត្តកំណែទម្រង់ទូទៅរបស់ ក្រសួងអប់រំ យុវជន និង កីឡា និង កម្មវិធីអាទិភាពជាក់លាក់នានា ។ អគ្គាធិការដ្ឋាន នឹងរៀបចំចាត់ចែងការងារ ទាំងនេះ និង សម្របសម្រួលការបែងចែករបាយការណ៍ការងារនៅក្នុងក្រសួងទាំងមូល ។ អគ្គនាយកទាំងអស់ នឹងសម្របសម្រួលការពិនិត្យតាមដានការរីកចម្រើន និង ផលប៉ះពាល់នៅតាមនាយកដ្ឋាន ដែលស្ថិតនៅក្រោម ឱវាទរបស់ខ្លួន ព្រមទាំងធ្វើការពិនិត្យតាមដានឱ្យបានទៀងទាត់ ជាមួយមន្ត្រីគ្រប់គ្រងជាន់ខ្ពស់របស់ខ្លួនផងដែរ ។

នាយកដ្ឋានហិរញ្ញវត្ថុ មានភារកិច្ចសម្របសម្រួលការពិនិត្យតាមដានការបំពេញការងារហិរញ្ញវត្ថុទូទៅ ដោយ គិតទាំងការបញ្ចេញ និង ការដកសាច់ប្រាក់សម្រាប់កម្មវិធី ។ នាយកដ្ឋានហិរញ្ញវត្ថុមានភារកិច្ចចុះពិនិត្យ តាមដាន និងធ្វើការអង្កេត ដើម្បីធានាថាការងារទាំងឡាយអនុវត្តបានត្រឹមត្រូវ តាមនីតិវិធីហិរញ្ញវត្ថុរបស់ រាជរដ្ឋាភិបាល ។

នាយកដ្ឋានផែនការមានភារកិច្ច សម្របសម្រួលការពិនិត្យតាមដានការបំពេញការងារវិស័យអប់រំ រៀបចំ របាយការណ៍រីកចម្រើន និង ផលប៉ះពាល់របស់កម្មវិធីនានា រៀបចំរបាយការណ៍ស្តីពីកម្មវិធីសាកល្បងរបស់អ្នក ផ្តល់ជំនួយ និង អង្គការក្រៅរដ្ឋាភិបាល និង រៀបចំប្រភពព័ត៌មានផ្សេងៗទៀត ។ នាយកដ្ឋានផែនការក៏មាន ភារកិច្ចចុះអង្កេតផលប៉ះពាល់ និង ការស្រាវជ្រាវលើការងារជាក់ស្តែងតាមការចាំបាច់ ។

អធិការដ្ឋានអប់រំ មានភារកិច្ចសម្របសម្រួលការងារពិនិត្យតាមដានការបំពេញការងារវិស័យអប់រំ លើ ផ្នែកគរុកោសល្យ រៀបចំរបាយការណ៍ស្តីពីការកែលំអគុណភាព និង ប្រសិទ្ធភាពនៃសេវាអប់រំលើគ្រប់ទិដ្ឋភាព រៀបចំរបាយការណ៍ស្តីពីគុណភាព និង ប្រសិទ្ធភាពនៃសេវាអប់រំ និង រៀបចំព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងគុណភាព និង ប្រសិទ្ធភាពអប់រំនៃការសិក្សា បរិស្ថានសិក្សា ខ្លឹមសារកម្មវិធីសិក្សា ឯកសារសិក្សា លំនាំបង្រៀន និង រៀន សម្ភារសិក្សា សម្ភារបរិក្ខារ អភិបាលកិច្ច និង ការគ្រប់គ្រងដោយមានការចូលរួមពីសហគមន៍ ។

នាយកដ្ឋានជំនាញនីមួយៗ នឹងរៀបចំការពិនិត្យតាមដានកម្មវិធីជាក់លាក់នានា ទៅតាមជំនាញរៀងៗខ្លួន ក្រោមការសម្របសម្រួលពីអគ្គនាយកដ្ឋាន ។ នាយកដ្ឋានទាំងនោះ ត្រូវធ្វើការពិនិត្យតាមដានសកម្មភាពនៅទូទាំង ២៤ ខេត្ត-ក្រុង ព្រមទាំងគ្រប់សកម្មភាពដែលមាននៅក្នុងកម្មវិធីនីមួយៗ ។ នៅពេលទទួលបានរបាយការណ៍ពីខេត្ត-ក្រុង នាយកដ្ឋាននីមួយៗត្រូវប្រមូលចងក្រងរបាយការណ៍រីកចម្រើនទាំងផ្នែកហិរញ្ញវត្ថុ និង ផ្នែកបច្ចេកទេស ទៅតាមកម្មវិធីនីមួយៗ ។ អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ត្រូវផ្សព្វផ្សាយរបាយការណ៍ទាំងនេះ ។ នាយកដ្ឋាននីមួយៗដែលទទួលបន្ទុកលើកម្មវិធីជាក់លាក់រៀងៗខ្លួន ក៏ត្រូវរៀបរបាយការណ៍ប្រចាំឆ្នាំស្តីពីផលប៉ះពាល់លើកម្មវិធីទាំងនោះផងដែរ ។ របាយការណ៍ទាំងនេះនឹងប្រើប្រាស់ជាមូលដ្ឋានសម្រាប់រៀបចំរបាយការណ៍បំពេញការងារវិស័យអប់រំប្រចាំឆ្នាំ ហើយនឹងត្រូវផ្សព្វផ្សាយក្នុងឱកាសពិនិត្យឡើងវិញកម្មវិធីគាំទ្រវិស័យអប់រំប្រចាំឆ្នាំ ។

នាយកដ្ឋាននៅថ្នាក់កណ្តាល ដែលមានថវិកាសម្រាប់ពិនិត្យតាមដានកម្មវិធីជាក់លាក់ នឹងធ្វើការបែងចែកថវិកាដល់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង និង ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក-ខ័ណ្ឌឱ្យបានសមស្រប ដើម្បីធានាឱ្យការពិនិត្យតាមដានកម្មវិធី បានអនុវត្តប្រកបដោយប្រសិទ្ធភាព ។ ផែនការការងារសម្រាប់ពិនិត្យតាមដាន នឹងរួមបញ្ចូលទាំងការផ្តល់ថវិកាដល់អគ្គាធិការដ្ឋាន នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ និង នាយកដ្ឋានផែនការឱ្យបានសមស្រប ។

មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង ត្រូវពិនិត្យតាមដានការរីកចម្រើននៃសកម្មភាពនានារបស់កម្មវិធីនីមួយៗ សំដៅធ្វើអោយសកម្មភាពទាំងនោះបានបញ្ចប់ប្រកបដោយប្រសិទ្ធភាព និង ទាន់ពេលវេលា ។ ក្រុមពិនិត្យតាមដានថ្នាក់ខេត្ត-ក្រុង ក៏ត្រូវតាមដានលំហូរនៃការផ្តល់ថវិការបស់កម្មវិធី ដល់សាលារៀន-គ្រឹះស្ថានសិក្សា ។ មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង ត្រូវផ្តល់ថវិកាដល់ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក-ខ័ណ្ឌឱ្យបានគ្រប់គ្រាន់ សម្រាប់ការងារចុះពិនិត្យតាមដាន និង ជួយជាប្រចាំដល់សាលារៀន ។ ក្រុមទាំងនេះនឹងផ្តល់ការជួយគាំទ្រផ្នែកបច្ចេកទេស និងការណែនាំផ្សេងៗ ជាពិសេសទៅដល់ថ្នាក់ស្រុក-ខ័ណ្ឌ និងកំរងសាលារៀន។

### ៩.៣ ការពង្រឹងប្រព័ន្ធព័ត៌មានស្តីពីការពិនិត្យតាមដាន

នាយកដ្ឋានផែនការ មានភារកិច្ចដឹកនាំការសម្របសម្រួលការងារប្រមូលព័ត៌មានស្តីពីការបំពេញការងារទូទាំងវិស័យដែលចាំបាច់ និង ធ្វើការវិភាគលើព័ត៌មានទាំងនោះ ។ ការប្រមូល និង ការវិភាគព័ត៌មានដែលមានភាពជាក់ស្តែង និងទាន់ពេលវេលា ជាការចាំបាច់ដើម្បីយកទៅកសាងផែនការរបស់ក្រសួងអប់រំ យុវជន និង កីឡា ក៏ដូចជារបស់រាជរដ្ឋាភិបាល និង សកម្មភាពពិនិត្យឡើងវិញនានា ។ សកម្មភាពសំខាន់ៗរួមមាន :

ក- ប្រមូល និង វិភាគទិន្នន័យ និង អាំងឌីកាទ័រគោល ដែលអនុវត្ត ៣ ដងក្នុងមួយឆ្នាំរបស់នាយកដ្ឋានផែនការ ។

ខ- ជំរឿនស្ថិតិសាលារៀន និង ការបោះពុម្ពសៀវភៅស្ថិតិ និង អាំងឌីកាទ័រអប់រំប្រចាំឆ្នាំ ដែលអនុវត្តដោយប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ របស់នាយកដ្ឋានផែនការ ។

គ- រៀបចំរបាយការណ៍បំពេញការងារវិស័យអប់រំ របស់ថ្នាក់កណ្តាល និង ខេត្ត-ក្រុង នៅមុនពេលធ្វើការពិនិត្យឡើងវិញរួមគ្នាប្រចាំឆ្នាំលើកម្មវិធីគាំទ្រវិស័យអប់រំ រវាងក្រសួងអប់រំ យុវជន និង កីឡា អ្នកផ្តល់ជំនួយ និង អង្គការក្រៅរដ្ឋាភិបាល ការងារនេះសម្របសម្រួលដោយនាយកដ្ឋានផែនការ ។

ឃ- សម្របសម្រួល និង គ្រប់គ្រងរបាយការណ៍រីកចម្រើនរបស់កម្មវិធីសកម្មភាពជាអាទិភាព ទាំងផ្នែកបច្ចេកទេស និង ហិរញ្ញវត្ថុផ្ទៃក្នុងរៀងរាល់ត្រីមាស ។

ង- អង្កេតអំពីការពេញចិត្តរបស់អ្នកប្រើប្រាស់ និង មាតាបិតាសិស្ស ដោយធ្វើការសិក្សាពីបញ្ហាពាក់ព័ន្ធ (ដូចជាភាពក្រីក្រ និង យេនឌ័រ) និង ផលប៉ះពាល់នៃគំរោងសាកល្បងនាពេលកន្លងមក និង កំពុងអនុវត្តរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

ច- កែលំអកម្មវិធីគាំទ្រវិស័យអប់រំប្រចាំឆ្នាំ ដោយពិចារណាទៅលើការបំពេញការងារវិស័យអប់រំទាំងមូល ដែលនឹងអាចធ្វើការកែតម្រូវកម្មវិធីអាទិភាពដែលមានស្រាប់ ហើយដាក់ឱ្យអនុវត្តកម្មវិធីថ្មី ឬ កាត់បន្ថយកម្មវិធីដទៃទៀតជាបណ្តើរៗ ។

នាយកដ្ឋានសម្ភារៈ និង ទ្រព្យសម្បត្តិរដ្ឋ ទទួលខុសត្រូវក្នុងការសម្របសម្រួលការពិនិត្យតាមដាន និង ធ្វើរបាយការណ៍អំពីកម្មវិធីសម្ភាររូបវ័ន្ត ។ នៅក្នុងនាយកដ្ឋាននេះមានអង្គភាពគ្រប់គ្រងគំរោងសម្ភាររូបវ័ន្តដែលត្រូវប្រើប្រាស់ ដើម្បីកំណត់ស្តង់ដាប្រព័ន្ធព័ត៌មានពិនិត្យតាមដាន និង របាយការណ៍ ទាំងខាងផ្នែកបច្ចេកទេស និង ហិរញ្ញវត្ថុ ។ ក្រសួងអប់រំ យុវជន និង កីឡា នឹងកំណត់ស្តង់ដានៃបណ្តាញរបាយការណ៍របស់គំរោងដល់អគ្គនាយកនានា ដែលស្របទៅតាមតួនាទីសម្របសម្រួលរបស់គាត់ផ្ទាល់ ។ តួនាទីរបស់មន្ត្រីគ្រប់គ្រង មន្ត្រីបច្ចេកទេស និង បុគ្គលិកអនុវត្តគំរោងនៃក្រសួងអប់រំ យុវជន និង កីឡា ក៏ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ផងដែរ ។ នីតិវិធីដដែលនេះ នឹងដាក់ឱ្យអនុវត្តចំពោះកម្មវិធីសាកល្បងខ្នាតតូច ដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលនានាផងដែរ ។

អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ទទួលខុសត្រូវក្នុងការផ្សព្វផ្សាយជាប្រចាំនូវព័ត៌មានស្តីពីការពិនិត្យតាមដានកម្មវិធី និង ការបំពេញការងារវិស័យអប់រំ ទាំងផ្នែកបច្ចេកទេស និង ផ្នែកហិរញ្ញវត្ថុ ទៅដល់អ្នកប្រើប្រាស់សំខាន់ៗ ទាំងនៅក្នុង និង ក្រៅក្រសួងអប់រំ យុវជន និង កីឡា ដែលនៅក្នុងនោះមាន :

**ក-** ពិនិត្យឡើងវិញនូវយន្តការនានា ដើម្បីធានាថាកម្មវិធីគាំទ្រវិស័យអប់រំរយៈពេលមធ្យមនេះ បានដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពរយៈពេលវែងរបស់ការអប់រំសម្រាប់ទាំងអស់គ្នា ។

**ខ-** រៀបចំសន្និបាតអប់រំ ដើម្បីធានាឱ្យមានការពិគ្រោះយោបល់រវាងអង្គភាពជំនាញនៅរដ្ឋបាលកណ្តាល មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត-ក្រុង និង ដាក់បញ្ចូលព័ត៌មានដែលទទួលបានពីមូលដ្ឋានទៅក្នុងការពិភាក្សាអំពីការបំពេញការងារវិស័យអប់រំ ។

**គ-** ផ្តល់ព័ត៌មានដល់សង្គមស៊ីវិលដូចជា មាតាបិតាសិស្ស ក្រុមប្រឹក្សាឃុំ-សង្កាត់ និង ក្រុមសហគមន៍ផ្សេងៗទៀត អំពីកិរិតនៃការរីកចម្រើនរបស់គោលនយោបាយ និង អ្វីខ្លះដែលពួកគាត់អាចជួយបាន ។

នាយកដ្ឋានផែនការ និង លេខាធិការដ្ឋាននៃការអប់រំសម្រាប់ទាំងអស់គ្នា ត្រូវសម្របសម្រួលសកម្មភាពរួមគ្នា ដើម្បីធានាឱ្យមានការពិនិត្យឡើងវិញជាប្រចាំនូវគោលនយោបាយ យុទ្ធសាស្ត្រ និង កម្មវិធីនានារបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និង កម្មវិធីគាំទ្រវិស័យអប់រំរយៈពេលមធ្យម ។